មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

icj International Commission of Jurists

# សេចក្តីថ្លែងការណ៍រួម

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងគណៈកម្មការអ្នកច្បាប់អន្តរជាតិ អំពាវនាវជាថ្មីម្តងទៀតឱ្យព្រឹទ្ធសភាផ្អាកកិច្ចពិភាក្សាលើច្បាប់ពាក់ព័ន្ធនឹង "កំណែទម្រង់" តុលាការ

ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ២០១៤

នៅថ្ងៃនេះ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) និងគណៈកម្មការអ្នកច្បាប់អន្តរជាតិ (ICJ) សូមជំរុញឱ្យព្រឹទ្ធសភានៃប្រទេសកម្ពុជាពន្យារសេចក្តីសម្រេចរបស់ខ្លួនដើម្បីពិនិត្យឡើងវិញទៅលើច្បាប់កំណែទម្រង់ផ្នែកតុលាការចំនួន ៣ នៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ និងស្នើឲ្យបើកកិច្ចពិគ្រោះយោបល់ជាមួយសាធារណជន និងសង្គមស៊ីវិល ក្នុងគោលបំណងកែលម្អនូវច្បាប់នេះដើម្បីធានាថា ច្បាប់ទាំងនេះអនុលោមតាមបទដ្ឋានអន្តរជាតិនានា។

ស្ថាប័នទាំងពីរនេះ បានលើកឡើងថា ប្រសិនបើព្រឹទ្ធសភាមិនអាចកែប្រែ និងមិនអាចធ្វើឱ្យច្បាប់ទាំងនេះស្របតាមច្បាប់ និងបទដ្ឋានអន្តរជាតិនានាទេនោះ ព្រឹទ្ធសភាគួរតែច្រានចោលនូវច្បាប់ទាំង ៣ នេះ។

ក្នុងចំណោមក្តីបារម្ភនានា ច្បាប់ទាំងនេះផ្តល់អំណាចដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌គ្រប់គ្រងហួសហេតុទៅលើកិច្ចការផ្នែករដ្ឋបាលជាច្រើនរបស់តុលាការ និងការងាររបស់ព្រះរាជអាជ្ញា ដែលកិច្ចការទាំងនេះគួរតែស្ថិតនៅក្នុងរង្វង់សមត្ថកិច្ចរបស់អាជ្ញាធរទាំងនោះទៅវិញនោះទេ។ ឧទាហរណ៍ មាត្រា ៣៩ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជាអ្នកធ្វើសេចក្តីសម្រេចដ៏សំខាន់ក្នុងការតំឡើងមុខតំណែងរបស់ចៅក្រម និងព្រះរាជអាជ្ញា។ បន្ថែមលើនេះទៀត មាត្រា ២៣ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចែងថា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌នឹងទទួលបន្ទុកក្នុងការត្រួតពិនិត្យ និងស្រាវជ្រាវបឋមលើសំណុំរឿងវិន័យផ្នែកតុលាការ។

កាលពីម្សិលមិញ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៤ គណៈកម្មាធិការអចិន្ត្រៃយ៍នៃព្រឹទ្ធសភាបានសម្រេចថា កិច្ចប្រជុំពេញអង្គនឹងប្រព្រឹត្តទៅនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៤ ដើម្បីពិនិត្យ និងផ្តល់យោបល់លើច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា និងច្បាប់ស្តីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

លោក ឌុច ពិសិដ្ឋ អ្នកសម្របសម្រួលគម្រោងសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ថ្លែងថា *"យើងមានការខកចិត្តចំពោះដំណឹងដែលថាការអំពាវនាវរបស់យើងឲ្យមានការពិនិត្យឡើងវិញទៅលើច្បាប់ទាំងនោះកាលពីដំបូងត្រូវបានព្រឹទ្ធសភាមិនអើពើ។ តែផ្ទុយទៅវិញបែរជាព្រឹទ្ធសភាពន្លឿនការ*

*ពិភាក្សា និងបានប្រងើយកន្តើយចំពោះការអំពាវនាវរបស់សង្គមស៊ីវិលឲ្យមានការពិគ្រោះយោបល់លើច្បាប់ទាំងនោះទៅវិញ។"*

ច្បាប់ទាំង ៣ នេះ ត្រូវបានរដ្ឋសភាអនុម័តយ៉ាងតក់ក្រហល់ដោយគ្មានការជំទាស់ នៅថ្ងៃទី ២២ និងថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៤។

របៀបអនុម័តស្រដៀងគ្នានេះ រំពឹងថានឹងកើតមាននៅព្រឹទ្ធសភា ពីព្រោះថា ព្រឹទ្ធសមាជិករបស់គណបក្សប្រឆាំងទំនងជាបន្តធ្វើពហិកាក្នុងការចូលកាន់អាសនៈរបស់ខ្លួន បន្ទាប់ពីមានការចោទប្រកាន់ពីការលួចបន្លំក្នុងការបោះឆ្នោតកាលពីឆ្នាំមុននេះ។

ប្រសិនបើសេចក្តីព្រាងច្បាប់ទាំងនេះ នឹងត្រូវបានអនុម័តជាស្ថាពរក្នុងទម្រង់ដដែលនោះ នឹងប្រគល់អំណាចហួសហេតុដល់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ហើយនឹងធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់ឯករាជ្យភាពរបស់តុលាការនៅកម្ពុជា។

ច្បាប់ដែលស្ថិតនៅក្នុងទម្រង់ចុងក្រោយនេះបំពានយ៉ាងជាក់ស្តែងដល់គោលការណ៍នៃការបែងចែកអំណាច និងឯករាជ្យភាពរបស់តុលាការ។ គោលការណ៍ទាំងនេះត្រូវបានបង្កើតឡើងយ៉ាងច្បាស់លាស់ដោយច្បាប់ និងបទដ្ឋានអន្តរជាតិនានា រួមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលប្រទេសកម្ពុជាជារដ្ឋភាគី និងគោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីឯករាជ្យភាពនៃតុលាការ ក៏ដូចជាសេចក្តីថ្លែងការណ៍ទីក្រុងប៉េងកាំងស្តីពីគោលការណ៍ឯករាជ្យភាពនៃតុលាការ។

លោកឃីងស្លី អែបត់ ទីប្រឹក្សាច្បាប់អន្តរជាតិរបស់កម្មវិធីតំបន់អាស៊ី ប៉ាស៊ីហ្វិក របស់គណៈកម្មការអ្នកច្បាប់អន្តរជាតិ មានប្រសាសន៍ថា "*នៅក្នុងប្រទេសណាក៏ដោយ ជាការចាំបាច់ដែលយន្តការការពារណាមួយត្រូវតែអនុវត្តការពារតុលាការពីការជ្រៀតជ្រែកមិនត្រឹមត្រូវពីសំណាក់ក្រុមផ្សេងៗ រួមទាំងស្ថាប័ននានារបស់រដ្ឋាភិបាលផងដែរ ជាការគួរឲ្យសោកស្តាយផងដែរ ច្បាប់ទាំងនេះមិនបានបំពេញនូវការធានាដល់តុលាការនោះទេ ហើយនឹងខកខានក្នុងការធ្វើឲ្យប្រសើរឡើងដ៏ពិតប្រាកដដល់ប្រព័ន្ធតុលាការនាពេលបច្ចុប្បន្ននេះ។"*


**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

**១) លោក ឌុច ពិសិដ្ឋ អ្នកសម្របសម្រួលគម្រោងសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក តាមរយៈទូរសព្ទ៖ +៨៥៥ (០) ១២ ៧១ ២៣ ៧១ ឬ តាមរយៈអ៊ីម៉ែល ៖ duchpiseth@cchrcambodia.org ។**

**២) លោក ឃីងស្លី អែបត់ ទីប្រឹក្សាច្បាប់អន្តរជាតិរបស់ ICJ តាមរយៈទូរសព្ទ + ៦៦ (០) ៩៤ ៤៧០ ១៣៤៥ ឬតាមរយៈអ៊ីម៉ែល៖ kingsley.abbott@icj.org។**